Khmer Story Lovers

# បោកហើរណៈ

— ទីចាត់ការនៃក្រុមអ្នកនិពន្ធមាតុភូមិ ផ្ទះលេខ ២៥ ផ្លូវលេខ ២៧៥ ជីឡូត៍លេខ ២៥៥ បឹងកេងកង សង្កាត់លេខ ៥ ក្រុងភ្នំពេញ —

## ប្រលោមលោកចេញផ្សាយរៀងរាល់ថ្ងៃ



ស៊ីឈ៊ិនពន្យល់ :

–នេះជារឿងចាស់មានមកតាមសម័យឆ្នាំណាយហើយ សេនាចាំងពីរនៅក្នុងផ្ទះហើយកូន ៗ មេក្រុមចាំងអស់ ទទួលផ្កាកបញ្ជាកាលណា គេតែងសួរគេអ្នកអញ្ជើញ ភ្ញៀវភ្លាម, ប៉ុន្តែសេនាចាំងពីរតែងបញ្ជាក់ថា កាលណាអញ្ជើញទៅលេងគេ ភ្ញៀវកំពុងសង្ឃឹមនឹងជួបស ហើយមិនបាច់សួរទេ ៗ នាយក្រុមបក្សខ្លះសើច ញឹម ៗ ខ្លះទឹងប្រឡេត... សេនាចាំងពីរបានបញ្ជាក់ទៀតថា អស់លោកណាទទួលបញ្ជាទៅកាន់គោរគាម ពាក្យសន្យានឹងបានសេចក្ដីសុខ បើពុំនោះសោតអ្នកនោះនឹងទទួល គ្រោះថ្នាក់ជាប់ជីវិត ៗ ក្នុងពិធីនេះ, កាលណោះក្រុមភ្ញៀវ ចាំងឡាយពិគ្រោះគ្នា គេព្រម ឬ មិនព្រមគោរពបញ្ជាក្ដី ៗ នាយក្រុមដែលបានទទួលបញ្ជាមុនគេ គឺស៊េស៊ីវសាន នាក់ក្រុម ជេងសេង ៗ កាលណោះគេទទួលផ្កាកស្លាក់ចាំងពីរ, សើចក្អាកក្អាយ ហើយចំរើនកម្លាំងប្រយាត់ផ្កាកស្លាកទៀងមួលគុំ ប្រើការ ពែងហើត ៗ ស៊េស៊ីវសានធ្វើបែបនេះដើម្បីបង្ហាញស្មៈដៃថាគាត់ មានកម្លាំងណាគុប៉ុណ្ណា ឲ្យសេនាចាំងពីរភ័យបាត់ស្មារតីត្រឡប់ ទៅវិញ ៗ ប៉ុន្តែពុំនអើយ, ស៊េស៊ីប្រយាត់ផ្កាកស្លាកភ្លាម ស្រែនចាំងពីរ យ៉ាងដែរព្រមគ្នា ត្រូវដើមទ្រូងស៊េស៊ីវសានជួលស្ទុះមួយបរំពេរ ៗ

អ្នកប្រែសម្រួល : អ.គឹមសាន

តម្លៃ ៣ រ ០០

ផ្សាយចេញពីក្រុមអ្នកនិពន្ធ
«មាតុភូមិ»
ភ្នំពេញ
លេខ ២៩

ស៊ីផណានភ្នាក់មាត់ស្រុក :

- យី ! ពួកនេះកាចសាហាវណាស់ហ្ន៎ !

- ក្រុមឥសីឃើញអ្នកក្លាហានដ៏ល្បីល្បាញស្លាប់ចាន់ហាន់នៅទីនោះ ក៏ស្ទុះស្ទាទម្លាយព័ទ្ធយុវជនចំនីតីរជាប់ ។ កាលណោះសេនាចំនីតីរមិនទាន់ខ្លាំងក្លាដូចពេលនេះទេ , គេខំដណ្ដើមជាំពីឥសីប៉ិខាត់វាយកេច្រកវង់ដោះខ្លួនរត់បាត់ទៅ ។ ប៉ុន្តែក្រុមចេនីសេនីមានអំណាចនិងកេរ្តិ៍ឈ្មោះល្បីល្បាញពេញពិភពគុន ណាក់រឿងនេះមិនដឹងទេ ។ ប្រហែលកន្លះខែក្រោយមក អ្នកគុននិយមវាល់រូបមិនជឿថាយុវជនចំនីតីរនោះ សម្លាប់នាយក្រុមចេនីសេនីដល់ទីកន្លែង ហើយរត់បាត់ ។ មួយថ្ងៃក្រោយរឿងហេតុនៅក្រុមចេនីសេនីផ្ទុះម្ដងទៀត គឺនាយក្រុមដឹកនាំមួយរូបត្រូវគេចាប់កំពុងប្រារព្ធពិធីជប់លៀងបុណ្យចម្រើនអាយុគំរប់ហុកសិបឆ្នាំ ស្រាប់តែឃើញយុវជនចំនីតីរទៅហុចផ្កាកស្ទាន់ឲ្យគាត់ ។ ភ្ញៀវកិត្តិយសទាំងអស់ឃើញអំពើប្រមាថមាក់ងាយបែបនេះ ក៏ខឹងនេះឆ្លេះ នាំគ្នាឡោមព័ទ្ធភ្លាម ។ កូនស្មុខមិនទាន់ល់ទេ, កាលណោះសេនាចំនីតីររត់រួចដោយងាយទៀត ! បីថ្ងៃក្រោយមក ក្រុមគ្រួសារលោកនាយក្រុមដឹកនាំគ្នាប្រហែលសាមសិបនាក់ស្លាប់អស់គ្មានសល់មួយ ។ នៅលើខ្លោងទ្វារផ្ទះគាត់ គេឃើញផ្កាកស្ទាន់ពីរបោះជាប់ក្នុងសាច់ឈើ ។

ស៊ីផណានឋគផ្ញើមធំ :

- ញ៉ី ! លើកដំបូងបង្អស់ខ្ញុំឃើញផ្កាកស្ទាន់ចំនីតីរលើមាត់ទ្វារទូករបស់ក្រុមគ្រូ ហោះមិនស្គាល់ថា... គេផ្ញើសំបុត្រយមរាជសោះ !

- ព្រោះហេតុហ្នឹងហើយ ទើបគេនាំគ្នាហៅផ្កាកស្ទាន់ចំនីតីរថា «បណ្ណមរណៈ» ណាំកូន ! កាលបើរឿងនេះផ្សាយចេញគ្រប់ទិសទីហើយ មានព្រឹទ្ធាចារ្យខាងក្រុមសៅលីនដ៏មួយរូបអញ្ជើញនាយក្រុមទាំងអស់ក្នុងពិភពគុនបើកសម័យប្រជុំមួយ ពិភាក្សាអំពីមធ្យោបាយទប់ទល់នឹងសេនាបណ្ណមរណៈនិងជៀសវាងមហន្តរាយ ។ ក្នុងពេលជាមួយគ្នានោះ គេបាត់ដឹងគ្នាគាបជានស៊ើបដំណឹងសេនាចំនីតីរផង តែយុវជនមួយរូបនេះគ្រាប់ចាប់រួចស្រមោលម្ដងក្រង់ណោះម្ដងក្រង់ណោះ ហើយប្រសប់កុងមុខមាត់ថែមទៀតផង ។ ពេលណាគេប្រុងប្រយ័ត្ន, វាមិនបង្ហាញស្រមោលឡើយ តែបើប្រហែសបន្តិចវាលេចមកពីក្រហែងណាភ្លាម បញ្ជូនផ្កាកស្ទាន់មកសាបព្រោះគេយន្តរាយក្នុងពិភពគុនយើងទៀត ។

សេនាចំនីតីរមិនត្រឹមមានដំណើរអាថ៌កំបាំងទេ, វាចេះយុទ្ធសិល្បៈខ្លាំងក្លាណាស់ហើយចេះប្រើពិស

ពុលកំណាចយ៉ាងប៉ុនប្រេសប់ទៀតផង ។ ព្រះតេជព្រះគុណសានពិនខាងក្រុមសៅលីងជី និងឥសីខ្ចក្ខូ នៃក្រុមអ៊ូគាំងសុទ្ធតែងគ្រោះដោយសារបញ្ចាមរណៈ ។ ចាស់ទុំទាំងពីរទទួលផ្ទាកបញ្ចាហើយ គាត់បំផ្លាញចោលភ្លាមតែមិនដឹងហេតុអី មួយខែក្រោយមកគាត់មានកេសាញ៉ាញ៉ីបាត់បង់ជីវិតបន្តបន្ទាប់គ្នា ។

ក្រោយមកអ្នកគុននិយមគ្រប់រូបពិចារណាថាព្រះតេជព្រះគុណសានពិននិងឥសីខ្ចក្ខូមានយុទ្ធសិល្បៈខ្ពង់ខ្ពស់ពេក ទើបសេនាទាំងពីរធ្វើអ្វីលោកមិនបាន ដែរជាប្រើមធ្យោបាយថោកទាបលាបថ្នាំពិសលើផ្ទាកស្លាន់ឲ្យអស់លោកប៉ះពាល់ទៅជាតិពិសជ្រាបចូលក្នុងកាយឈឺប្រហែលមួយម៉ោងសោះក៏ស្លាប់យ៉ាងអាណោចអាធ័ម...ហ៊ឺ ! ពិសពាលចសាហាវណាស់ ។

ស៊ុំផងានព្រឺក្បាលសំពោងបន្ទឹមថា:

– បងធម៌ខ្ញុំទាំងពីរដែលឈ្មោះចាងសាននិងលីសែ នោះពិត... ពិតជាកំណាចប្លែកមែនឬ ? គាត់មានគំនុំអ្វីជាមួយក្រុមបក្សនានាក្នុងពិតពគុន ? ហេតុអ្វីក៏ធ្វើបាបគេម៉្លឹង ៗ ?

ស៊ុំឈឹងគ្រវីក្បាល :

– ជាងសាមសិបឆ្នាំមកហើយ គ្មាននរណាគេឃើញពេជ្ជកំបាំងឬពិចារណាឃើញហេតុផលនៃរឿងបញ្ចាមរណៈឡើយ ។

បន្ទាប់ពីដឹងថា ឥសីជីវសាននាយក្រុមគេងសេង, លោកនាយក្រុមដឹកនាំគ្រកូលទាវ ព្រមទាំងគ្រួសារ, ព្រះតេជព្រះគុណសានពិនខាងក្រុមសៅលីងជី និង ឥសីខ្ចក្ខូ ខាងក្រុមអ៊ូគាំង ដែលសុទ្ធសឹងជាអ្នកក្លាហានខ្លាំងពូកែបាត់បង់ជីវិត ដោយសារបញ្ចាមរណៈ, អ្នកគុននិយមឯទៀតក៏យបារម្ភរៀងរាល់ថ្ងៃ ។ អ្នកខ្លះទទួលផ្ទាកបញ្ចាភ្លាម យល់ព្រមទៅកាន់កោះចូលរួមពិធីជប់លៀងនៃគត្តិភ្លាម ។ សេនាទាំងពីរតែងពោលបញ្ជាក់ប្រាប់ថា :

– បើលោកយល់ព្រមអញ្ជើញទៅកោះឡូងមុ គឺជាកិត្តិយសមួយដ៏កម្រ , សូមលោកអញ្ជើញទៅរង់ចាំនៅកន្លែងមួយសិន , ដល់កំណត់ពេលវេលាដែលយើងសន្យា មានគេជិះទូកមកទទួលលោកទៅកាន់កោះតែម្ដង ។

ក្នុងមួយឆ្នាំនោះសេនាទាំងពីរបានលួចវាយឆ្មក់ ឬលួចដាក់ថ្នាំបំពុលគេស្លាប់អស់ដប់បួននាក់, ក្រៅពីនោះ មានដប់ប្រាំបួននាក់យល់ព្រមទទួលសេចក្ដីអញ្ជើញទៅជប់លៀងជបរ តែអ្នកទាំងដប់ប្រាំបួនឥតឃើញត្រឡប់មកវិញទេ ។ សាមសិបឆ្នាំផុតហើយ បាត់ស្រមោលរហូត !...

Khmer Story Lovers

ស៊ីមឆានស្អះ:

– កោះឡេនមុនៅត្រង់ណា ? ម៉េចក៏មិនប្រមូលគ្នាទៅជួយអ្នកតាំងជប់ប្រាំបួនឲ្យចេញផុតពីក្ដាប់ដៃគេ ?

– ឈ្មោះកោះឡេនមុ គ្មាននរណាស្គាល់សោះកូនអើយ ទោះសួរអ្នកដំណើរចប់ជប់ទន្លេណាំវៃ ក៏គ្មានអ្នកណាស្គាល់ដែរ ប្រហែលគ្មានរូបរាងទេ, សេនាតាំងពីរប្រឌិតផ្ដេសផ្ដាសហើយ !

ថ្ងៃទៅចេះតែកន្លងទៅ . . . ក្រៅពីក្រុមគ្រួសារញាតិមិត្តនៃអ្នកក្លាហានចំនួនសាមសិបរូប ដែលបាត់ខ្លួន , គេបំភ្លេចរឿងបញ្ហាមរណៈនោះហើយ មិនស្មានថាដប់ឆ្នាំក្រោយ ផ្កាស្គាន់បង្ហាញរូបរាងក្នុងពិភពលោកម្ដងទៀតសោះ ។ លើកនេះសេនាតាំងពីរពូកែលាស់ខាងវិស័យយុទ្ធសិល្បៈជាងមុនច្រើនណាស់ ។ ក្នុងរយៈកាលមួយថ្ងៃប្លាយប៉ុណ្ណោះវាបានប្រហារមនុស្សជាងមួយរយនាក់នៃក្រុមបក្សទាំងឡាយណាដែលមិនព្រមទទួលបញ្ហាមរណៈ ម៉្លោះហើយពិភពលោកច្រួលច្របល់សាជាថ្មី ។

ចាស់ទុំបីរូបខាងក្រុមម៉ៃអើបានកោះប្រជុំអ្នកក្លាហានប្រហែលម្ភៃនាក់ បបួលគ្នាទៅជួបស្ទាក់ដល់ក្រុមលំពែងខ្មៅដើម្បីលបចាប់ឃាតករតាំងពីរ ។ ប៉ុន្តែសេនាតាំងឆាត តាំងស្ដម គេចបាត់ពីដំរុក្រុមលំពែងខ្មៅទៅចែកផ្កាស្គាន់ដល់ក្រុមបក្សផ្សេងទៀតស្រេច ។ ឲ្យតែនាយក្រុមណាទទួលផ្កាស្គាន់, ក្រុមគ្រួសារគេតាំងមូលបានសេចក្ដីសុខជានិច្ច ។ ផ្ទុយទៅវិញទោះប្រយ័ត្នខ្លួនប្រុង មានការយាមល្បាតតឹងរ៉ឹងបែបណាក៏ចៀសមិនផុតពីមរណៈដែរ ។

ឆ្នាំមួយនោះលោកសានាយក្រុមនាគខ្មៅបានទទួលផ្កាស្គាន់ និងយល់ព្រមតាមសេចក្ដីអញ្ជើញ ។ បន្ទាប់មកគាត់លួចប្រាប់ពេលវេលានិងទីកន្លែងប្រជុំគ្នាឡើងទូកដល់ក្រុមលំពែងក្រហម ដើម្បីឲ្យអ្នកក្លាហានមួយក្រុមនោះជួបជុំគ្នានៅកន្លែងណាត់ ។ គ្រាន់តែប៉ុណ្ណឹងក៏លេចឮដល់សេនាតាំងពីរដែរ, ដល់ថ្ងៃសន្យាគ្មានឃើញនរណាមកទទួលសោះ ។ គេរង់ចាំមើលទូកអស់ប៉ុន្មានថ្ងៃនៅតែមិនឃើញ ហើយក្នុងរយៈពេលនោះអ្នកក្លាហានត្រូវជាតិពិសញាំញីស្លាប់បន្តគ្នារលុយ ។ អ្នកនៅរស់តិចប៉ុន្មានក៏ភ័យពេកនាំគ្នាបែកផ្លូវត្រឡប់ទៅកន្លែងវិញរៀងខ្លួន ។

នៅតាមផ្លូវគេបានទទួលដំណឹងថាអ្នកស្រុកសែនៅក្នុងផ្សារស្លាប់បាត់បង់ជីវិតយ៉ាងកាចកំហុំង ជាទីបំផុត ។ ក្នុងឆ្នាំដដែលនោះមានអ្នកដឹកនាំប្រាំបីរូបធ្វើដំណើរទៅកោះឡេនមុ ឥតឃើញត្រឡប់មកវិញសោះ ប្រហែលស្លាប់ក្នុងសមុទ្រអស់ហើយ ។ តាំងអស់នេះជាគ្រោះថ្នាក់សំរាប់ពិភពលោក

នឹកឃើញកាលណាគេភ័យស្លុតនិងសោកស្ដាយរកទីបំផុតគ្មាន ។

ស៊ីផាននោះមិនជឿថាផងស្រុងក៏នាយញញើតព្រឺក្បាលសំពោងដែរ ព្រោះនាយឃើញសាកសពក្រុបត្រីហោះផ្លាស់ក្អែក , ឃើញក្រុមឬកដែកផ្លូវស្លាប់រណែល ដោយសារជាតិពិស គ្រប់បាតដៃនាយជាក់ស្ដែងណាស់ ។

ស៊ីឈីងពោលថា:

- ដប់ឆ្នាំបន្ទាប់មកទៀតនាយក្រុមវ៉ូវ៉ីបានទទួលផ្កាស្លាទ់មុនគេ ។ ឆ្នាំនោះមានអ្នកក្លាហានជាច្រើនប្រជុំគ្នាទៀតថា:

- ត្រូវចូលជាំខ្លាបាច់ក្លួនទៅបំផុតទុក្ខទោស ។

គេសម្រេចចិត្តទៅរកមើលកោះឡុងមុំឲ្យបានឃើញផ្លាស់ក្អែក ដើម្បីរួមកម្លាំងគ្នាកំចាត់សត្វរួមៗ តាំងពីនោះមិនលេចឮដំណឹងអ្វីពីអ្នកក្លាហានទាំងសាមសិបបីរូបនោះ , ឈ្មោះកោះឡុងមុំក៏ធ្វើឲ្យករព្រឺកពីគតគុនហេតុមក ។

អាស្រមសាំងឈីងរបស់ពុកលែងចេញមុខចេញមាត់លែងទាត់សិស្សណាដើរផ្សងព្រេងដូចមុន ។ ពុកនិងម៉ែឯងហាត់រៀនយុទ្ធសិល្បៈពីអាស្រមសាំងឈីងគ្រាន់តែបំពេញកិច្ចសង្គ្រោះគេបន្តិចបន្តួចក្នុងតាមភូមិឋាន ស៊ិនស៊ីប៉ុណ្ណោះ ។ ចំណែកគ្រូអ្នកគ្រូមាឯងទាំងប៉ុន្មានមានយុទ្ធសិល្បៈខ្លាំងពូកែមែន តែមិនដែលបានចេញទៅប្រយុទ្ធជាមួយអ្នកណាទេ, ម្ល៉ោះហើយអ្នកគុនពិភពលោកទូទៅតែងស្មានថាអាស្រមសាំងឈីងមានសុទ្ធតែស៊ាវរៀនធម៌ពុំចេះយុទ្ធសិល្បៈអ្វីទេ...

ស៊ីផានសួរគាត់:

-មកពីខ្លាចកោះឡុងមុំឬ ?

ស៊ីឈីងអេះអុញមួយស្របក់ទើបឆ្លើយ :

-គ្រូអ៊ំនិងគ្រូមាឯងសុទ្ធជាអស់កាន់សីលខ្ជាប់ខ្ជួនណាស់ មិនសូវនឹកនាដល់កត្តានាមក្នុងពិភពគុនទេ ចង់ថាខ្លាចកោះឡុងមុំក៏បានដែរ ព្រោះទាំងអស់គ្នាដឹងច្បាស់ហើយតើ ! ទោះពូកែយ៉ាងណាក៏ដោយឲ្យតែឮឈ្មោះកោះឡុងមុំឬបបរទៃកត្តិកគេព្រួយបារម្ភគ្រប់គ្នា ។ ពុកមិនស្មានថាអាស្រមសាំងឈីងដែលសុខសាន្តយូរហើយគេចមិនផុតពីគ្រោះថ្នាក់ដូច្នេះសោះ ។

ស៊ីឈីងពោលចប់ផ្ដើមយំ ។ ស៊ីផានសួរទៀត:

Khmer Story Lovers



-ពុកចង់ធ្វើនាយក្រុមអស្រមសាំងឈីង ដើម្បីទៅស៊ើបការណ៍នៅកោះឡង់មុខ ? បើមានមនុស្សដល់ទៅបីក្រុមស៊ើបការណ៍មុនបាត់ឈឹងហេតុដូច្នេះ ខ្ញុំយល់ថារឿងនេះពិបាកណាស់, មិនងាយសំរេចបានដូចបំណងទេឡើយ ។

ស៊ឹឈីងឆ្លើយទាំងស្រងូត :

- ពិតជាពិបាកហើយកូន ! ប៉ុន្តែពុកនិងម៉ែធ្លាប់ជួយដោះទុក្ខគេយូរឆ្នាំហើយ តែងបាត់ទុករឿងគ្រោះថ្នាក់ជាករណីយកិច្ចផ្ទាល់ទៅវិញ, ជាពិសេសគ្រោះថ្នាក់ធ្លាក់លើក្រុមបក្សយើងស្រាប់ , ឯងឲ្យពុកនិងម៉ែទុបដៃមើលនឹងភ្នែកម្តេចបាន ?

ស៊ឹផានងក់ក្បាល :

- បើយ៉ាងហ្នឹងពុកយល់ថា បាងសាននិងលីសៃ ជាសេនាដែលកោះឡង់មុខបាត់ឲ្យមក ចែកផ្លាកបញ្ហាឬ ?

ស៊ឹឈីងងក់ក្បាល :

-ប្រាកដហើយ !

-បើដូច្នេះម៉េចក៏មនុស្សគាបយោរយៅតាំងពីព្រមទទួលខ្ញុំជាប្អូនធម៌គេ ?

ស៊ឹឈីងអស់សំណើច ហើយពន្យល់:

-កាលណោះមិនដឹងតើកូនប្រើពាក្យមុតប្រាយយ៉ាងណា ទាល់តែជនកំណាចតាំងពីបដិសេធមិនបាន ? តែកូនកុំភ្លើ, ពីនាក់នោះបេះតែស្បថស្បែឲ្យរួចពីមាត់ទេ, គ្មានប្រយោជន៍សោះឡើយ ។

ស៊ឹផានសួរដោយឆ្ងល់:

- ស្បថយ៉ាងម៉េចឲ្យរួចពីមាត់ ហើយអត់បានប្រយោជន៍ ?

- ព្រោះជនកំណាចតាំងពីមិនប្រាប់ឈ្មោះពិតប្រាកដផងឯងណា ! បាងសាននិងលីសៃជាឈ្មោះប្រឌិតសុទ្ធសាធ ទោះស្បថឲ្យបាងសាននិងលីសៃរងទុក្ខវេទនាដូចផ្លែក្រៃយ៉ាងណា ក៏គ្មានពាក់ព័ន្ធដល់សេនាបញ្ញាមរណៈតាំងពីដែរ ។

- អូយល់ហើយ ! ពួកគេជាបងធម៌ក្លែងក្លាយទេតើ ! ចាំមើលថ្ងៃក្រោយជួបគាត់ទៀតខ្ញុំនឹងស្តីបញ្ជាក់ឲ្យច្បាស់លាស់ម្តង ។

អ្នកស្រីវុនយូរត្តុយស្ងៀមយូរហើយ ពោលភ្លាមថា :

- កូនយី, បើថ្ងៃក្រោយជួបបុរសទាំងពីរដែលប្រឡាក់សុទ្ធតែឈាមសម្លាប់មនុស្សឥតព្រិចភ្នែក ដែលជាឃាតករសាហាវយង់ឃ្នងនោះ , កូនតទល់ជាមួយគេមិនបានទេ ត្រូវរកមធ្យោបាយសម្លាប់ ដូចជាប្រើថ្នាំបំពុលជាដើម ។

ស៊ីឈីងយល់ស្របតាម ពោលបន្ត :

-កុំថាឡើយត្រឹមមនុស្សពុះពោះត្រង់ដូចរូបកូន, សូម្បីមនុស្សឆ្លាតវាងវៃហើយសម្បូរកិច្ចកល និងការពិសោធន៍ក៏មិនងាយរត់រួចពីកណ្តាប់ដៃសេនាទាំងពីរដែរ ។ តាមពុកយល់គឺថាប្រុងប្រយ័ត្នយ៉ាងណាក៏មិនឈ្នះវាដែរ, បើកូនជួបប្រទះពួកនោះមែនគប្បីបញ្ចេញស្នាដៃសម្លាប់វាមុនតែម្តងទៅ, សម្លាប់បានម្នាក់ទុកដូចជាជួយកំចាត់សត្រូវរួមពាក់កណ្តាលដែរ, ពិភពគុនទាំងមូលនឹងមិនចំភ្លេចឧបការគុណកូនទេ ។

ស៊ីផានសួរ :

- ពីរនាក់នោះជាបងធម៌ខ្ញុំ តើខ្ញុំអាចសម្លាប់បានដែរឬ ?

ស៊ីឈីងដកដង្ហើមធំពិចារណាថា :

- កូននេះផ្លាស់ប្តូរចិត្តគំនិតអស់ទាំងស្រុង បើប្រើវាទៅសម្លាប់បងធម៌ប្រហែលវាយល់ថាមិនសមមែនទេដឹង ?

អ្នកស្រីសើច :

- បងឈីងឃើញទេ , កូនយើងកែប្រែចិត្តគំនិតទាំងអស់ លែងខិលខូចដូចមុនទៀតហើយ ។

ស៊ីឈីងតបទាំងក្រៀមក្រំ :

- ហ៊ឺ ! ព្រោះតែគេឃើញវាស្លូតបូតយ៉ាងនេះហើយ ទើបគេទាក់ទាញវាមកធ្វើខែល សម្រាប់ទទួលគ្រោះថ្នាក់ជំនួសគេ .. កូនយី , កូនដឹងទេ ហេតុអីអ្នកក្វាហាន់ក្រុមឈានល្បូលើករូបកូនឲ្យធ្វើនាយក្រុម ?

ស៊ីផានមិនចេះពិហារណាមកពីនាយធ្លាប់រស់នៅក្នុងព្រៃភ្នំជាមួយម្តាយ ឥតដែលបានទាក់ទងនិយាយស្តីជាមួយនរណាសោះ ។ បន្ទាប់មកនាយរស់នៅលើភ្នំម៉ានជាមួយសិយានទីតែពីរនាក់ម៉ឹងទៀត ទៅជាល្ងីល្ងើមិនដឹងអី ។ តាមពិតនាយមានប្រាជ្ញាឈ្លាសវៃវាងវៃដែរ, គ្រាន់តែដើរជាមួយប្តីប្រពន្ធស៊ីឈីងនិងស្តាប់គាត់អធិប្បាយរឿងនេះហូរហែមកនាយយល់វែងឆ្ងាយភ្លាម ស្រែក

ក្វាក់សម្ដេច :

-គេលើកខ្ញុំជានាយក្រុម... គេគោរពខ្លាចខ្ញុំ... ឥឡូវគេចង់ឲ្យខ្ញុំស្លាប់ជំនួសគេហើយ ។

- ហ៊ឺ ! កិច្ចការអ្វីដែលមិនទាន់ច្បាស់លាស់ យើងមិនគួរមានចិត្តបង្វែរបង្អល់យល់ឃើញទុកមុន ដូចកន្ទុយអណ្ដើកទេ ។ ប៉ុន្តែមានចំណុចសំខាន់ៗ ជាច្រើន ដែលគួរពិចារណា ព្រោះ ទីមួយ ក្រុមឈានល្អមានសមាជិកខ្លាំងពូកែ ហើយគ្នាគេវាងវៃជាងកូនច្រើនណាស់, ហេតុអ្វីគេមិនជ្រើសរើសនាយក្រុម បែរជាលើកកូនឯងដែលនៅក្មេងល្អក់ ឥតស្គាល់កិច្ចការនៃពិភពគុនឲ្យ ធ្វើនាយក្រុមទៅវិញ ? ទីពីរក្រុមឈានល្អទើបនឹងលេចឮឈ្មោះប៉ុន្មានឆ្នាំនេះទេ ។ កាលពុកជួបកូននៅភូមិហ្វូវជាន ពុកមិនទាន់ឮឈ្មោះនេះសោះបានសេចក្ដីថាក្រុមឈានល្អមានអ្នកដឹកនាំឆ្លាតវៃគ្រាន់បើ គេដឹងថាសេនាបញ្ញាមរណៈជិតដល់កំណត់បេញមុខសាបព្រោះទុក្ខៈវេទនាក្នុងពិភពគុនទៀតហើយ, ត្រូវតែរកមនុស្សម្នាក់ផ្សេងធ្វើនាយក្រុមដើម្បីទទួលផ្លាកស្លាក ហើយមនុស្សដែលគ្មានជាប់សាច់សាលោហិត គឺរូបកូននេះតែម្ដង ។

មាណពស្ដាប់បណ្ដើរពិចារណាបណ្ដើរ ធ្វើភ្នែកស្រឹ ហាក់មិនទាន់ជឿថាមនុស្សលោកកាចសាហាវយង់ឃ្នងបែបហ្នឹងសោះ, តែស៊ុំឈើងវែកញែកសមហេតុសមផលណាស់មិនអាចមិនជឿបានឡើយ ។

អ្នកស្រីនុយជួយពន្យល់ :

-កូនឯយើ, ក្រុមឈានល្អមានឈ្មោះស្អុយគគ្រុកពេញពិភពគុនណាស់ ! ទោះមិនសម្លាប់មនុស្សដូចសេនាបញ្ញាមរណៈ គឺក្រុមនោះបណ្ដោតបណ្ដោយសមាជិកឲ្យប្រព្រឹត្តអំពើចាបថោកគ្រប់បែបយ៉ាងដែរ, ជាពិសេសគេអនុញ្ញាតឲ្យសមាជិករំលោភលើស្ត្រីគេតាមចំណង់ចិត្ត ។ ត្រង់នេះហើយដែលអ្នកគុននិយមសុចរិតស្អប់ខ្ពើមជាទីបំផុត ។ ចំណែកនាយក្រុមគេតាំងអម្បូលមាំនមិនមែនមនុស្សល្អទេ, គ្រូដឹងថាគេរៀបចំដាក់អន្ទាក់ចាំទទួលកូនណាំ ! រឿងនេះវាច្បាស់ដូចពីរនឹងពីរត្រូវជាបួនដូច្នោះឯង, មិនបាច់សង្ស័យទៀតឡើយ ។

ស៊ុំឈើងពោលតាំងក្ដៅក្រហាយ:

- ហ៊ឹះ ! កេនណាមិនកេ មករកប៉ះពាល់កូនយើ យើងតែម្ដង ! ពួកនោះគេញាប់ចិត្តគិតពីកាលបើដឹងថាកូនយើចិត្តល្អស្មោះត្រង់ថែមទាំងក្មេងវៀងវាស់អស់លើងទៀត, គេទាញខ្សែព្រាត់តាមចិត្តស្រេច ។ ប៉ុន្តែគេមិនស្មានថា លោកនាយក្រុមសំកប់ជះក្របីតួឯកកំនេះជាគ្រូប្រុសបង្កើត

របស់ម្ចាស់ភូមិមានសក្តិសម្បូរឈ្មោះស៊ុណ៉ីននិងរ៉ុនយូទេ ។ ក៏ះ កលឧបាយកខ្វក់ប្រាសចាកសីលធម៌នេះ មិនងាយសំរេចឡើយ ។

ពេលដល់នេះស៊ុណ៉ីនស្តាប់ដឹងថាវត្ថុប៉ៃណានប៉ុន្មានចិត្តសខាងកើតដែលជាទីតាំងក្រុមឈានល្អ ៗ អ្នកស្រីបន្ទឹកថា :

–យើងរកឃើញឧបាយកលខ្មៅងងឹតរបស់ក្រុមឈានល្អហើយ ឃើញថាអស់កន្លងមួយផ្នែកធំ ៗ ម៉្យាងទៀតជាការសំខាន់គឺកូនយើងមិនទាន់បានទទួលផលកស្តាន់នៅឡើយ ។ ដូច្នេះយើងគិតធ្វើម៉េច?

ស៊ុណ៉ីនសញ្ជឹងគិតបន្តិចទើបឆ្លើយ :

– យើងត្រូវនាំកូនទៅកាន់ក្រុមឈានល្អបើកកកាយរឿងនេះឲ្យគិតតគុនជំនួញជន ប៉ុន្តែធ្វើដូច្នេះយើងទៀសមិនផុតពីគំហើងក្រុមឈានល្អទេ មុខជាកើតការប្រយុទ្ធដ៏សាហាវមិនខាន ។ ហើយពេលនោះគ្នាយើងតែប៉ុនាក់ប្រហែលមិនឈ្នះពួកគេច្រើនទេ ម៉្យាងទៀតគួរតែអ្នកចាស់ទុំខ្លះធ្វើស្មាក្សីផង ទើបថ្ងៃក្រោយពួកនោះភាមធានៅកូនយើងមិនបាន ៗ

អ្នកស្រីឆ្លើយយ៉ាងរហ័ស :

– បងយ៉ាងនៅស្រុកជាស៊ីងស្គាល់គេច្រើនណាស់ ហើយត្រូវជាមិត្តយើងផង ។ គួរទៅរកគាត់ឲ្យជួយអញ្ជើញអ្នកគុនទិយបខ្លះទៅកាន់ក្រុមឈានល្អតែម្តងឬ ?

ស៊ុណ៉ីនត្រេកអរណាស់យល់ស្របភ្លាម :

– ប្រសើរណាស់ ! មិត្តភក្តិយើងនៅជាងណាន ប្រហែលមិនភ្លេចប្តីប្រពន្ធយើងទេ ។

គឺ្យតស៊ុណ៉ីននិងរ៉ុនយូមានឈ្មោះល្បីល្បាញក្នុងពិភពគុនយូរឆ្នាំមកហើយ ដោយសារគាត់មានចិត្តល្អ ធ្វើបុណ្យដាក់ទានដល់អ្នកក្រីក្រ និងជួយដោះទុក្ខបុរសអ្នកទន់ខ្សោយ តែមិនដែលបានពឹងពាក់នរណាម្នាក់វិញឡើយ ។ ពេលនេះគាត់សង្ឃឹមថា ទៅរកគេពិតជាគេជួយជ្រោមជ្រែងមិនខាន ។

ថ្ងៃនេះប្តីប្រពន្ធស៊ុណ៉ីននាំកូនប្រុសទៅស្រុកជាស៊ីង ។ បីថ្ងៃក្រោយមកគេឈប់ក្នុងផ្ទះសំណាក់មួយសំរាកកម្លាំង ។ ស៊ុណ៉ីននិងរ៉ុនយូនៅបន្ទប់លើខ្ពស់ ឯស៊ុងគានស្នាក់ក្នុងបន្ទប់មួយខាងក្រោម ៗ

អ្នកស្រីឡើញ្ញកូន,នឹកព្រួយកូនមិនចង់ឲ្យឃ្លាតទៅណាទេ, គាត់ចង់ឲ្យកូននៅបន្ទប់ជាប់គ្នាតែគ្មានមួយណាទំនេរសោះ ៗ

Khmer Story Lovers



កក្រើកនេះមាណពអន្ទះតែងក្នុងបំពើនកម្លាំងធាតុ ។ នាយទទួលអារម្មណ៍ដូចផែកផ្អើម ស្រួលណាស់ កម្លាំងធាតុកើតសព្វសព៌ាង្គកាយ... នាយណាបាតដៃមើលឃើញស្នាមក្រហមធំទៀវរលុបអស់ខ្លះហើយ ។ មាណពគិតដឹងថា ជាតិពិសជ្រាបចូលគ្រប់សរសៃសសូនទេ ស្នាមជាំរលាយអស់ ដោយសារកម្លាំងធាតុផ្សេងៗចេញទៅក្រៅផុតបាតដៃ ទើបមានចិត្តត្រេកអរ, ប្រះខ្លួនផេកកាយ ។

ដល់ពាក់កណ្ដាលអធ្រាត្រស្រាប់តែឮសម្លេងគុកៗ យ៉ាងស្រាលដូចមាននរណាហៅនាយ ត្រង់មាត់បង្អួច ។ មាណពស្ទុះក្រោកក្លែកសួរតិច ៗ :

- អ្នកណាហ្នឹង ?

សម្លេងគោះបង្អួចឈ្ងុំងឹងទៀត យ៉ាងស្រាលប៉ុន្ដែហាក់ស្ទាត់ជំនាញណាស់បណ្ដាលឲ្យ ស៊ីផានភ្ញាក់ព្រើតសួរទៀត:

- អ្នកណា ? ទីងកុងឬ ?

សម្លេងមួយឆ្លើយពីក្រៅតិច ៗ :

- ខ្ញុំមែនហើយ , បងស្មានថាអ្នកណាផ្សេងឬ ?

ស៊ីផានស្គាល់ជាក់ជាទីងកុងក៏ភ័យផងអរផង រកនិយាយតបវិញលែងកើត ។ ពេលនោះឮ ខ្វាក ! គ្រវាសពាសបង្អួចរហែកមួយផ្ទាំង ហើយលេចដៃទីងកុងស្លុតលូកមកចាប់ច្បិកត្រចៀកនាយមួយយ៉ាងខ្ទាំង ។ ទីងកុងស្រែកសួរ :

- ម៉េចបងមិនព្រមបើកបង្អួច ?

ស៊ីផានឈឺណាស់ តែមិនហ៊ានស្រែកខ្លាចភ្ញាក់ពុកម្ដាយនៅខាងលើ ទើបម្នីម្នាបើកបង្អួចខ្វាក ! ទីងកុងលោតចូលមកស៊ើបទឹក ១ :

- បងបានឃ្លា ! បងនឹកខ្ញុំទេ ?

មាណពអេះអុញរកពាក្យឆ្លើយមិនបាន ។ ទីងកុងគំហកសួរ :

- អស្ចារ្យណាស់ ! បងបាន ! បងឯងឥតនឹកខ្ញុំទេឬ ? នឹកតែកូនក្រមុំថ្មីដែលសំពះផ្អឹមក្រោយខ្ញុំនោះឬ ?

មាណពស្ទះណាយក្បុកក្ដើល:

- ខ្ញុំមានសំពះផ្ទឹមជាមួយអ្នកណាទៀត ?

- អើស ចង់ប្រកែកផងឬ? ខ្ញុំឃើញផ្ទាល់ភ្នែកណា! ណ្ហើយ! ឥឡូវខ្ញុំមិនប្រកាន់ទេព្រោះបងធ្លាប់ចិត្តខូចបែបនេះយូរហើយ ។ ខ្ញុំក្រោកទៅវិញទេ ... ឥឡូវនាងនោះទៅឯណា ?

- ទៅបាត់ហើយ... ខ្ញុំត្រឡប់ទៅរកនាងមិនឃើញសោះ ។

ចិនគុនសើចកក្អឹក:

- សូមទោសភរិយាកុំក្តុកកែស្អែកគ្នាជួយខ្ញុំ កុំឲ្យបងការទរកនាងនោះឃើញណាអើយ !

- ចុះដ៏ភ្ញាចិនៗ គុនៗ ឯងនៅឯណា, សុខសប្បាយជាទេឬ ?

ចិនគុនលូកដៃក្ដិចមួលថ្ពាល់ណាពត់មាត់ :

- សូមបងកុំសួរបានទេ ? អូយ . . .

នាងក្រមុំស្រែកព្រោះកម្លាំងណាពុមាណពេញប្រាណប្រមាត់ដៃទាំងខ្លាំងមកវិញយ៉ាងចាស់ៗ ស៊ីផានឥតដឹងខ្លួនទេ, ពោលបន្ទោរក្រើយ:

- ចិនៗគុនៗ ... អូនឯងកាត្រក់ណាស់, ហ៊ានត្រាត់បងចោលក្នុងទឹកទន្លេ ... បើគ្មានទូកគេមកជួយម្ល៉េះស្លាប់បាត់ទៅហើយ ។

- យី! បើកុំតែបានទូកយ៉ាងម៉េច? ព្រោះតែមានទូកម៉្លឹងហើយបានជាខ្ញុំបោះបង ណា! មិនដឹងទេហ្ន៎ ?

ស៊ីផានធ្វើមុខអៀនប្រៀន:

- ខ្ញុំដឹងខ្លះដែរ ជាមួយប្រឡាញ់បង ... តែ ... ហាមាត់និយាយមិនបាន... ខ្ញុំអៀនណាស់

-ចិនគុនសើចនៅក្នុងប្រឹះបន្ទោស:

- យើងជាប្ដីប្រពន្ធស្រាប់ហើយតើមានអៀនអីគ្នាទៀតសាអៀន ?

យុវជនប្រុសស្រីអន្ទងទន្ទឹមគ្នាហើយត្រូវ ។ ស៊ីផានកុំកួនចិនគុនក្រឡូបកាយ ១ នាយព្រាស់ព្រាលណាស់នឹកក្នុងពោលថា :

- ឪពុកម្ដាយយើងនៅស្ងប់ទាំងពេលកនឹងរឿងនេះផង យើងត្រូវសួរពោបយល់គាត់សិនតើគាត់យល់ព្រមឲ្យយើងទទួលចិនៗ គុនៗ ជាប្រពន្ធដែរ ?

នាយចង់លូកដៃស្រវាចាប់ចិនគុន... គ្រាន់តែលូកដៃប៉ះនាងក្រមុំភ្លាម, នាយដកចេញភ្លាមធ្វើ

ឲ្យច័ន្ទគុនសង្ស័យសួរភ្លាម :

– បងណាន, ប្រាប់ខ្ញុំឲ្យត្រង់មកមើល៍ ? រូបខ្ញុំនិងប្រពន្ធថ្មីរបស់បង, . មួយណាស្អាតជាង ?

– យ៉ីអើ ! ប្រពន្ធថ្មីណាអ៊ីចេះ ? ខ្ញុំមាន... មានតែច័ន្ទគុនម្នាក់ប៉ុណ្ណោះដែលជាប្រពន្ធ...

ច័ន្ទគុនត្រេកអរពេកស្រវាឱបក្បាលនាយប៉េចខ្សែតយ៉ាងរហ័ស ។ ស៊ុំផានខ្មាសក្រហមមុខមិនដឹងគិតធ្វើដូចម្តេច ព្រោះគេប្រកែកមិនកើត ហើយចង់ពាច់ខុចនាងវិញតែមិនហ៊ាន ។ ចំណែកច័ន្ទគុនក្រោយពីប្រព្រឹត្តអំពើខុសទំនៀមទម្លាប់ស្រីក្រមុំហើយ នាងនឹកស្តាយក្រោយ ហើយខឹងខ្លួនឯងណាស់, នាងបង្រួញខ្លួនប្រុះដេកលើគ្រែស្រវាឆ្នួយមកគ្រលុំផិត ។ ស៊ុំផានរុញកម្ពួយប្រមក់ទើបហៅតិចៗ :

– ច័ន្ទគុន.. ច័ន្ទគុន...

ច័ន្ទគុនមិនឆ្លើយសោះ, មាណពដេកដង្ហើមដំរក្រោកទៅអង្គុយក្រោមលើគ្រែដេកលក់ទៅ ។

ច័ន្ទគុនឃើញមាណពខុសត្រូវឲ្យនាងដេកម្នាក់ឯងដូច្នេះនាងគិតថា :

– យើងទាំងស្វែងរកគាត់គ្រប់ទិសទីបន់អស់ពេលច្រើនថ្ងៃណាស់, ឥឡូវបានជួបដូចបំណងមែន !

នាងក្រមុំកាយផ្លែអស់កម្លាំងផងក៏សម្រេចដេកលក់ទៅ ។

ព្រលឹមស្រាង ៗ ឮសម្លេងគោះទ្វារ ហើយឮអ្នកស្រីវុនយូស្រែកហៅ :

–កូនយ៉ី, ក្រោកហើយនៅ ?

ស៊ុំផានឆ្លើយបាទ ! ស្ទុះក្រោកងាកមើលច័ន្ទគុន,ឈរទើទើរង់ចាំនាងឲ្យយោបល់ ។ អ្នកស្រីពោលពីក្រៅទៀតថា:

– កូនយ៉ីបើកទ្វារមើល៍, ម្តាយចង់និយាយនឹងកូនបន្តិច ។

មាណពឆ្លើយបាទ ៗ តែនៅឈរកេសមុងទ្វារច័ន្ទគុនអៀនខ្មាសក្រៃលែង ។ ដោយនឹកថាខ្លួនជាស្រីមកដេកសំណាក់ក្នុងបន្ទប់មួយតែពីរនាក់ស៊ុំផានមិនសក្តិសមនឹងក្នុងអ្នកក្រៅទេ តោះខ្លួនឥតបានប្រព្រឹត្តល្មើសនឹងច្បាប់ប្រពៃណីក៏ដោយ ។ ជាពិសេសទៅទៀតអ្នកដែលចង់ចូលមក ជាអនាគតក្មេកនាង គាត់ជឿលក្ខណ៍នាងថាម៉េចទៅ ? ក្រែងអ្នកស្រីមិនទទួលជាកូនប្រសាទេដឹង ?

នាងងាកមើលបង្អួចប្រុងលោតចេញតែនាងងាកមើលមុខស៊ុំផាននឹកស្តាយទៅវិញ:

-យើងចាំស្វែងរកគាត់អស់កម្លាំងផង លំបាកលំបិនផងទំរាំឃើញ ។ ឥឡូវបែកគ្នាភ្លាម ប្អូនម្ដេចឡើយយើងដាច់ចិត្ត តើថ្ងៃណាខែណាយើងជួបគ្នាវិញ ។

នាងត្រូវតែធ្វើសញ្ញាមិនឲ្យអ្នកកម្លោះបើកទ្វារ តែមាណពពោលតិចៗ :

-ម្ដាយខ្ញុំទេតើ ! ខ្លាចអី ?

នាយលូកដៃដល់ទ្រុកទ្វារបំរុងបើកទៅហើយ, ចិនគុងនឹកថា :

-បើអ្នកដទៃខ្ញុំឥតខ្លាចទេ, ព្រោះតែខ្លាចត្រង់ម្ដាយបងនោះណា៎ !

នាងបង់លោកតាមបង្អួចគេចខ្លួនតែនាងស្ដាយស៊ីផានមិនចង់បែកពីនាយសោះ ។

## វគ្គទី ២៨

## ក្រុមអ្នកក្លាហាននៅលាចគុង

ចិនគុងមិនដែលខ្លាចអីមែន តែកាលៈទេសៈនេះនាងញញើតអ្នកស្រីរុនយូមខាតម្ដាយក្មេក ព្រោះនាងមិនចង់ជួបមុខគាត់ក្នុងស្ថានភាពមិនគប្បីដូច្នេះ ។

នាងខ្មាសអៀនក្ដៅខ្លួនពី ក្រឡេកទៅស៊ីផានឃើញឱបប្រុងចាប់តាញទ្រុកទ្វារ នាងភ័យណាស់ ញាក់ដៃទ្រូងសំដែងស្លៀកបាប់ខាំចុងពីតបមោយដាប់, ដៃស្ដាំសំដែងស្លៀកកាប់ផ្កាពោលស្ទឹក ចុងពីតបត្រង់ចង្កេះ ។ ស៊ីផានមិនទាន់ឬាក់ស្រឡាំងកាំងផង, ចិនគុងរាប់ឆ្លូសនាយទៅក្នុងក្រោមគ្រែស្រេប ។

អ្នកស្រីរុនយូជាអ្នកក្លាហានជើងចាស់, គ្រាន់តែស្ដាប់សម្លេងស្រោកស្រាកក្នុងបន្ទប់ ក៏យល់ថា មានហេតុការណ៍អ្វីមួយភ្លាម ។ គាត់ស្រឡាញ់កូនណាស់ ផ្អៀងស្មាប្រុកផ្ទាំងទ្វារបើកខ្ទាត, ស្ទុះចូលដល់បន្ទប់ឃើញបង្អួចចំហ អ្នកស្រីប្រហែលជាពោះទុំ រកមើលកូនប្រុសឥតឃើញសោះ គាត់ស្រែកហៅប្ដីយ៉ាងខ្លាំង :

- បងឈើងចុះមកឆាប់ឡើង !

ស៊ីឈើងកាន់ដាវមកដល់ភ្លាម , រុនយូពោលញ័រៗ :

-កូនបី... នរណាចាប់កូនយើងបាត់ហើយ!

អ្នកស្រីចង្អុលបង្អួច... ប្ដីប្រពន្ធទាំងពីរលោតចេញតាមបង្អួចដ៏ណាការគ្នា ប្រៀបដូចសត្វស្លាបមួយគូ

ធ្វើឲ្យចិនគុនដែលពួនក្រោមគ្រែ អត់ទ្រាំនឹងសើចសសើរមិនបាន ។

បើយោលលើគំនិតប្រាជ្ញានិងយុទ្ធសិល្បៈប្ដីប្រពន្ធស៊ីណឺងមិនគួរចាញ់កលចិនគុនទេ, ប៉ុន្តែនេះមកពីឪពុកម្ដាយស្រឡាញ់កូនពេកឈឺឆ្អាលពេកទៅជានឹកមិនដល់ ហ្វេនស៊ីនអស់ស្មានថាក្រុមគ្លីកកម្ពុក្រុមឈានលួចពួនគ្នីគ្នាមកចាប់យកទៅវិញ ។

កាលអ្នកស្រីបុកទ្វារចូលមកមិនឃើញកូនប្រុស គាត់យល់ថាគេនាំវាចេញទៅបាត់ហើយ, ហើយគាត់ជឿជាក់ថា គាត់ដេញទាន់ជាដាច់ខាតទើបមិនរវល់ពិនិត្យក្នុងបន្ទប់ឲ្យសព្វគ្រប់ខ្លាចខាតពេលវេលា ។ ព្រោះហេតុប្ដីប្រពន្ធគាត់យល់ថាឆ្ងាយពេក ទើបបបួលគ្នាដេញតាមសត្រូវយ៉ាងរហ័ស ។

នៅក្នុងបន្ទប់សិណាក់ស៊ុំផានអាចកម្រើកដៃជើងបានវិញដោយសារគេប៉ាំងធាតុនាយស្រាយដំពេរខ្លួនឯង ។ នាយប្រុងស្រែកហៅឪពុកម្ដាយដែរ តែចិនគុនឧបជាប់ក្ដាបមាត់នាយថែមទៀត ទើបនាយស្រែកហៅមិនកើត ។ គាលីយតែចីទើរប្ដីប្រពន្ធស៊ីណឺងរត់ចេញទៅបាត់អស់ ។ ពេលនោះផ្ទួលក្រោមគ្រែហុយចូលច្រមុះនាយពេញ នាយកណ្ដាស់ខ្ទេចខ្ទារហើយទាញចិនគុនចេញមកក្រៅ ។ នាងក្រមុំបុះក្របាមផល់គុម្ពត្រចៀកឃើញស្រស់គួរឲ្យចាប់ចិត្តណាស់ ។ ស៊ុំផានពោលបញ្ជាក់ :

- គាត់ជាឪពុកម្ដាយខ្ញុំទេ [illegible] គុនឯ !

- ខ្ញុំដឹងហើយមិនបាច់[illegible]ប្រាប់ទេ , យប់មិញខ្ញុំលួចពីហៅគាត់ពុកៗ ... ម៉ែៗ ..

- ចាំមើលបន្តិចទៀតគាត់ត្រឡប់មកវិញហើយ , កូនចាំជួបគាត់ណា !

ចិនគុនខ្ទ្រុំដើងគ្រវីក្បាល :

- ទេ ! ឪពុកម្ដាយបងម៉េចអាយជីតាខ្ញុំណាស់ , ដូចជាមើលងាយរូបខ្ញុំដែរ ។

ស៊ុំផានឆឹកដល់សំដីសំរោងនិងពាក្យពេចន៍ឪពុកម្ដាយ គួររយៈពេលដើរដេកនិងហាត់រៀនជាមួយនាយប៉ុន្មានថ្ងៃនេះ ឃើញថាស៊ីណឺងនិងវុនបរូចេះដឹងជ្រៅជ្រះប្លុកពាថ្ងៃថ្នូរខុសឆ្ងាយពីចិនមិនប្លូសបីដូចមេឃនិងដី ម៉្លោះហើយនាយមិនហ៊ានសម្រេចចិត្តក៏សួរនាងក្រមុំ :

- ឥឡូវយើងគិតយ៉ាងម៉េច ?

ចិនគុនជឿជាក់ថាបន្តិចទៀតប្ដីប្រពន្ធស៊ីណឺងត្រឡប់មកវិញ, នាងតបភ្លាម :

- បងទៅបន្ទប់ខ្ញុំសិន, ខ្ញុំមានការនិយាយ ។

Khmer Story Lovers



- អូ, អូនសំណាក់ក្នុងផ្ទះនេះដែរ ?

- បាស ! បើមិនឲ្យខ្ញុំនៅទីនេះ បងគិតថាខ្ញុំនៅឯណា ?

ពោលហើយ នាងដើរទៅឈរមាត់បង្អួច សម្លឹងមើលខាងក្រៅឥតឃើញមនុស្ស ទើបបោយដៃហៅមាណពលោកតាមបង្អួចចេញទៅកាន់បន្ទប់មួយតូច ។ ស៊ីផានសួរដោយឆ្ងល់ :

- ជីតាអូននៅឯណាដែរ ?

- ខ្ញុំលែងនៅជាមួយលោកតាហើយ, ខ្ញុំលួចរត់មករកបងតែម្នាក់ឯងទេ ។

-ហេតុអីបានជាមកម្នាក់ឯង ?

នាងក្រមុំធ្វើមុខក្រញូវ :

-ហ៊ុះ ! នៅសួរទៀតហ្ន៎ ! លោកតាមិនព្រមឲ្យខ្ញុំស្វែងរកបងឯង, មានតែខ្ញុំលួចរត់ទើបមកបានៗ

ស៊ីផានរំភើបចិត្តពោលសរសើរ :

-ទីងៗតុងៗ . . . អូនល្អនឹងខ្ញុំណាស់ ។

ទីងតុងរីកថ្លើមប្រមាត់ពោលទាំងញញឹមស្រស់ :

-យប់មិញបងឥតនិយាយដូច្នេះទេ, ម៉េចក៏ថ្ងៃនេះបងលែងអៀនខ្មាសហើយ ?

មាណពញញឹមតបវិញ :

- ព្រោះអូនថាយើងជាប្ដីប្រព. ? ម៉. ត្រូវអៀនខ្មាសអ្វី ?

ទីងតុងសប្បាយផងអៀនខ្មាសផង ឡើងក្រហមថ្ពាល់ម្ដងទៀត ។

ខណៈនោះឮសម្លេងគោកគោកទៅត្រង់ទ្វារផ្ទះសំណាក់ហើយឮស៊ីឈីងពោលខ្លាំងៗ :

- ពេលនេះប្រាក់ថ្លៃបន្ទប់ ។

បន្ទាប់មកគឺស្នូរជើងសេះរណ្ដំគ្នាយ៉ាងញាប់ ។ ស៊ីឈីងចិនវ័យយូបំបោលសេះតាមដានកូនប្រុសសម្លាញ់យ៉ាងប្រញាប់ ស្នូររណ្ដំកាន់តែឆ្ងាយទៅៗ រហូតលែងឮអ្វីសោះទើបស៊ីផានសួរទីងតុង :

- អូនស្គាល់ស្រុកផាស៊ីននៅត្រង់ណាទេ ?

- ស្រុកផាស៊ីនធំណាស់ , នរណាក៏ស្គាល់ដែរ ។

- ពុកនិងម៉ែជាទៅស្រុកផាស៊ីនរកមិត្តម្នាក់ឈ្មោះយានឡុង ... បន្តិចទៀតយើងទៅតាមក្រោយមុខជាជួបហើយ ។

មាណពពោលបែបនេះព្រោះមិនចង់បែកពីចន្ទកុមារ ចំណែកនាងក្រមុំបែរជាគិតឃើញផ្សេងថា៖

- បងផានមិនស្គាល់ផ្លូវទេ, ស្រុកជាប្អូននៅទិសអគ្នេយ៍ បើពិតនាំគាត់ទៅទិសឦសានវិញ កុំឲ្យគាត់ជួបឪពុកម្ដាយកើតការស្មុគស្មាញ ។

នាងក្រមុំពេញចិត្តនឹងការសម្ងាត់របស់ខ្លួនក៏បញ្ចេញទឹកមុខរីកស្រស់ប្រិមប្រិយ ។ ស៊ីផាន មើលមុខនាងក្រមុំបើកភ្នែកក្រឡេក ដោយងឿងឆ្ងល់, ចន្ទកុមារសួរ៖

- បងមិនដែលឃើញខ្ញុំទេឬ ? មើលក៏មើលមិនដាក់ភ្នែកអីចឹង ?

ស៊ីផានញញឹម៖

- ចន្ទកុមារ... មួនស្អាតណាស់, ស្រស់ណាស់, ល្អមើលជាងម្ដាយខ្ញុំទៅទៀត!

ចន្ទកុមារសើចក្អឹកៗ៖

- បងផានឯងក៏ស្អាតដែរ. ល្អមើលជាងឪពុកខ្ញុំទៅទៀត!

អ្នកទាំងពីរផ្ទុះសំណើចក្អាកក្អាយ... គេសំរេកសំណាលគ្នាដោយរីករាយ តែស៊ីផាននៅព្រួយ ឪពុកម្ដាយមិនបាត់ ពោលញញឹកញញ័យ៖

-ពុកចង់តែមើលខ្ញុំមិនឃើញពិតជាព្រួយបារម្ភណាស់, យើងគប្បីចេញដំណើរទៅ ។

- ទៅក៏ទៅ... កូនកញ្ញា...

ចន្ទកុមារកាត់ប្រាក់មួយដុំលើតុ, ហើយនាំគ្នាចេញទៅក្រៅ ។ ម្ចាស់សណ្ឋាគារព្រម ទាំងភ្ញៀវឯទៀតងឿងឆ្ងល់ដូចគ្នាដោយឃើញមាណពតូចលមកស្ដួលដុំជាមួយប្រពន្ធស៊ីណើង ព្រោះតែ ព្រឹកមិញនេះបញ្ចេញដំណើរជាមួយស្រីក្រមុំទៅវិញ ។

អ្នកទាំងពីរបោកចេញពីផ្ទះបាយនេះគេប្រង់ទិសខាងកើត, បានចម្ងាយប្រហែលពាក់យាមផង គេមក ដល់ផ្លូវបំបែកជាបី ។ ចន្ទកុមារមិនខ្វល់ពីការណា, នាំស៊ីផានដើរសំដៅទិសឦសានភ្លាម ។ មាណព ស្លូតជានានឹងស្គាល់ផ្លូវហើយក៏ដើរទន្ទឹម នាងក្រមុំពោលថា៖

- សេះរបស់ពុកខ្ញុំដែលមិនលឿនណាស់ណា ! បើគាត់មិនចាំយើងទេ, គង់ផ្លូវតាមគាត់ទាន់ ឡើយ ។

Khmer Story Lovers

(នៅមានត)